FAO

អង្គការស្បៀង
អាហារ និង កសិកម្ម
នៃសហប្រជាជាតិ

សេចក្តីណែនាំបច្ចេកទេស
ដើម្បីភាពទទួលខុសត្រូវ
វិស័យជលផល

៥



# ការអភិវឌ្ឍវារីវប្បកម្ម

FAO
សេចក្ដីណែនាំបច្ចេកទេស
ដើម្បីភាពទទួលខុសត្រូវ
វិស័យជលផល

# ការអភិវឌ្ឍវារីវប្បកម្ម

ម.ព.ឯ.ក AIDOC
Code: 137-008
Date:
Donated by:

អង្គការស្បៀងអាហារ និង កសិកម្មនៃសហប្រជាជាតិ
ទីក្រុងរ៉ូម ឆ្នាំ១៩៩៧

FAO

អង្គការស្បៀង
អាហារ និង កសិកម្ម
នៃសហប្រជាជាតិ


សេចក្តីណែនាំបច្ចេកទេស
ដើម្បីភាពទទួលខុសត្រូវ
វិស័យជលផល

៥

# ការអភិវឌ្ឍវារីវប្បកម្ម


សហការផលិតដោយ
នាយកដ្ឋានជលផល និង JICA ខែវិច្ឆិកា ២០០៣
ឧបត្ថម្ភថវិកាដោយ JICA

ការរៀបចំដែលបានធ្វើឡើង និង អត្ថន័យនៃអត្ថបទទាំងមូលដែលបានបោះពុម្ពផ្សាយនេះពុំមែនឆ្លុះបញ្ចាំងទស្សនៈ ទោះជានៅក្នុងផ្នែកណាមួយរបស់អង្គការស្បៀងអាហារ និង កសិកម្មនៃសហប្រជាជាតិលើការងារច្បាប់របស់ប្រទេស ដែនដី ទីក្រុង តំបន់ ឬ លើការងារគ្រប់គ្រងនៃអាជ្ញាធរផ្ទាល់ ឬ ពាក់ព័ន្ធទៅនឹងការកំណត់តំបន់ដែលត្រូវគ្រប់គ្រងឡើយ ។

រក្សាសិទ្ធគ្រប់យ៉ាងដោយនាយកដ្ឋានជលផល ។ គ្មានផ្នែកណាមួយនៃឯកសារនេះត្រូវបានបោះពុម្ពចំលងឡើងវិញ រក្សាទុកក្នុងប្រព័ន្ធដែលរកបានមក ឬ បញ្ជូនទៅវិញទៅមកតាមរូបភាព ឬ ដោយមធ្យោបាយណាមួយដូចជាៈ អេឡិចត្រូនិច មេកានិច ថតចំឡង ឬ មធ្យោបាយផ្សេងទៀតដែលមិនបានសុំការអនុញ្ញាតពីអ្នករក្សាសិទ្ធិជាមុនឡើយ ។ រាល់ការស្នើសុំត្រូវភ្ជាប់មកជាមួយនូវគោលបំណង និង វិសាលភាពនៃការបោះពុម្ពឡើងវិញត្រូវតែផ្ញើមកនាយកដ្ឋានជលផល អាសយដ្ឋានលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារលេខ (៨៥៥) ២៣ ២១៥ ៤៧០ ប្រអប់សំបុត្រលេខ ៥៨២ ។

© ជ.ផ ២០០៣

បកប្រែសម្រួល និង បោះពុម្ពឡើងវិញ ឆ្នាំ ២០០៣

| បកប្រែសម្រួលដោយ | ពិនិត្យកែសម្រួលដោយ |
|---|---|
| - លោក ម៉ៅ សំអុន | - លោក ណៅ ធូក |
| - លោក ហាវ វិសិដ្ឋ | - លោក សម នៅ |

ការអភិវឌ្ឍវារីវប្បកម្មដែលឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ប្អូនៗ សិស្សានុសិស្ស និង មិត្តរួមអាជីពទាំងអស់កំពុងកាន់អាននៅក្នុងដៃនេះត្រូវបានបកប្រែសម្រួល រៀបរៀង ចងក្រង ហើយបោះពុម្ពយ៉ាងសម្រិតសម្រាំងចេញពីសៀវភៅជាភាសាអង់គ្លេសដែលមានចំណងជើងថា " Aquaculture Development " ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍវិស័យវារីវប្បកម្មរបស់ប្រទេសជាតិក្នុងដំណាក់កាលបច្ចុប្បន្ន ។

ការអភិវឌ្ឍវារីវប្បកម្មត្រូវបានបកប្រែមកជាភាសាជាតិការប្រើពាក្យពេចន៍ទាំងអស់ដែលមាននៅក្នុងសៀវភៅនេះគឺផ្អែកទៅតាមវចនានុក្រមខ្មែរដែលជាការចេញផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១១ គ.ស. ១៩៦៧ ។

ចំពោះខ្លឹមសារបច្ចេកទេសដែលមាននៅក្នុងសៀវភៅទាំងមូល យើងខ្ញុំបានពិនិត្យកែសំរួលផ្ទៀងផ្ទាត់ សាចុះសាឡើងជាច្រើនលើក ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ យើងខ្ញុំជឿជាក់ថាពិតជានៅមានខ្វះចន្លោះខ្លះៗជាមិនខាន ទោះបីដោយចេតនា ឬ អចេតនាក្តី ។

យើងខ្ញុំទាំងអស់គ្នារង់ចាំទទួលរាល់ការរិះគន់ ស្តាបនាពីសំណាក់អ្នកអានគ្រប់មជ្ឈដ្ឋានដោយសេចក្តីសោមនស្សរីករាយ ។

រាល់មតិ យោបល់រិះគន់កែលំអដើម្បីស្ថាបនាទាំងអស់ សូមផ្ញើមកនាយកដ្ឋានជលផលលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៥៨២ ឬ តាមរយៈ e-mail: nuov@mobitel.com.kh ។

ការរៀបចំឯកសារ

សេចក្ដីណែនាំនេះបានរៀបចំឡើងដោយនាយកដ្ឋានជលផល ឧបត្ថម្ភថវិកាដោយ JICA មតិ និង សំណូមពរនានាដែលមានក្នុងសេចក្ដីណែនាំសំរាប់ការអភិវឌ្ឍវិស័យជលផលដែលប្រកបដោយភាពទទួលខុសត្រូវសំរាប់ជាព័ត៌មានដើម្បីប្រឹក្សាបច្ចេកទេស ស្ដីពីក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងការធ្វើអាជីវកម្មនេសាទ នៅទីក្រុងរ៉ូម ពីថ្ងៃទី២៦ ខែកញ្ញា ដល់ ថ្ងៃទី ៥ ខែតុលា ឆ្នាំ១៩៩៤។ ក្នុងសេចក្ដីបញ្ចប់នៃឯកសារនេះមានការយកចិត្តទុកដាក់ផ្ដោតទៅលើមតិ និង សំណូមពរបន្ថែមនានាដែលទទួលបាន និង ដើម្បីភ្ជាប់ទៅនឹងទស្សនៈផ្សេងៗរបស់ជំនាញការនៅក្នុងបណ្ដាកិច្ចប្រជុំអន្តរជាតិសំខាន់ៗ និង/ឬ ការបោះពុម្ពផ្សេងៗ ។ ឯកសារនេះត្រូវបានរៀបចំក្រោមការសំរបសំរួលរបស់ R.L. Welcomme និង U.Barg ស្ដីពីធនធានទឹកសាប និង សេវាវារីវប្បកម្ម និង មានបន្ថែមបទពិសោធន៍ដែលទទួលបានពីបុគ្គលិកដែលធ្លាប់បានធ្វើការពាក់ព័ន្ធទៅនឹងនិន្នាការ និង ការអភិវឌ្ឍនានាដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងវិស័យវារីវប្បកម្ម។ លោក M. Lizarraga, A. Van Houtte, C. Leria, W. Edeson, K.grainger, A. Bonzon, D. Greboval, E. Ruckes, C. Lima Dos Santos, J. Kapetsky, H. Naeve, Z. Shehadeh, D. Bartley, R. Subasinghe, A. Tacon និង F. Henderson បានជួយ និង ចូលរួមចំណែកក្នុងកិច្ចខិតខំនេះតាមគ្រប់វិធី។

គួរកត់សំគាល់ថា សេចក្ដីណែនាំទាំងនេះមិនស្ថិតនៅក្នុងស្ថានភាពស្របច្បាប់ទេ ។ វាគឺជាការបំរុងទុកផ្ដល់ជាជំហ្វូន្មានទូទៅដើម្បីឧបត្ថម្ភគាំទ្រដល់ការអនុវត្តមាត្រា៩( ការអភិវឌ្ឍវារីវប្បកម្ម) នៃក្រមប្រតិបត្តិដែលប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល ។ ឯកសារនេះផ្ដល់ដល់អ្នកអាននូវការកត់សំគាល់តាមបែបទូទៅ និង ជាមធ្យោបាយដើម្បីបំរើឱ្យការណែនាំទូទៅ ហើយគួរចាត់ទុកដូចជាការផ្ដល់យោបល់ ឬ ការអង្កេតដើម្បីយកចិត្តទុកដាក់ នៅពេលប្រឈមមុខនឹងបញ្ហាដែលពាក់ព័ន្ធទៅនឹងការអនុវត្តកថាខណ្ឌនានារបស់ក្រមប្រតិបត្តិដែលប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល ។ម្យ៉ាងទៀតភាពខុសគ្នាជាយថាហេតុក្នុងការប្រើពាក្យបច្ចេកទេសគួរតែបានយល់ថាគឺជាការបកប្រែសំរួលឡើងវិញរបស់ក្រមប្រតិបត្តិ ។ គួរចងចាំបន្ថែមថា សេចក្ដីណែនាំបានត្រៀមបំរុងដើម្បីអាចបត់បែន និង សមត្ថភាពផ្លាស់ប្ដូរទៅតាមកាលៈទេសៈនៅពេលដែលមានការប្រែ

ប្រួលផ្សេងៗ ឬ ព័ត៌មានថ្មីៗដែលប្រែក្លាយទៅជាមានប្រយោជន៍ ។ សេចក្តីណែនាំនេះអាចកែសំរួល ហើយបំពេញបន្ថែមដោយសេចក្តីណែនាំ និង កំណត់ត្រាដទៃទៀត... ។ល ។ លើបញ្ហាជាក់ស្តែងហើយ មួយចំនួនបានស្ថិតក្រោមការបរិយាយយ៉ាងល្អិតល្អន់ដូចបានចង្អុលបង្ហាញក្នុងអត្ថបទនៃឯកសារនេះ ។ ចំពោះបញ្ហានេះ សូមអញ្ជើញអ្នកអានទាំងអស់ចូលរួមសហការជាមួយ FAO ផ្តល់ព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធបច្ចេកទេស គោលនយោបាយ និង បញ្ហាផ្សេងៗស្របច្បាប់ដែលអាចជាប្រយោជន៍ក្នុង ការកែលំអឱ្យទាន់សម័យ វាយតំលៃ និង ធ្វើឱ្យប្រសើរឡើងនូវឯកសារនេះ ដូចជាក្នុងការអភិវឌ្ឍ ឱ្យបានជាក់ស្តែងជាងនូវឯកសារណែនាំសំដៅជំរុញអភិវឌ្ឍវារីវប្បកម្មឱ្យប្រកបដោយភាពទទួលខុស ត្រូវដើម្បីចូលរួមវិភាគទានក្នុងការផ្គត់ផ្គង់ម្ហូបអាហារប្រកបដោយនិរន្តរភាព ។

**ការចូលរួមចំណែក ៖**

- គ្រប់សមាជិក FAO និង សមាជិកជាសហការីទាំងអស់ដែលបានចាប់អារម្មណ៍ អង្គការជាតិ និង អន្តរជាតិទាំងអស់
- នាយកដ្ឋានជលផលរបស់FAO
- ប្រធានការិយាល័យជលផលនៃFAO ក្នុងការិយាល័យថ្នាក់តំបន់ទាំងអស់របស់FAO
- អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលបានចាប់អារម្មណ៍

នាយកដ្ឋានជលផលរបស់FAO

ការអភិវឌ្ឍវារីវប្បកម្ម

សេចក្តីណែនាំបច្ចេកទេសរបស់FAO ដើម្បីភាពទទួលខុសត្រូវក្នុងវិស័យជលផល លេខ៥

ទីក្រុងរ៉ូមFAO ឆ្នាំ១៩៩៧ ៤០ ទំព័រ ។

## <u>សង្ខេប</u>

វារីវប្បកម្មគឺជាវិស័យមួយដែលរីកចំរើនរហ័សបំផុតក្នុងប្រព័ន្ធផលិតកម្មម្ហូបអាហារលើពិភព លោកជាមួយនឹងបន្ទុកនៃលទ្ធផលបច្ចុប្បន្នដែលបានផលិតក្នុងបណ្តាប្រទេសកំពុងរីកចំរើន ហើយ សង្ឃឹមជឿជាក់របស់វារីវប្បកម្មដើម្បីចូលរួមចំណែកក្នុងសុវត្ថិភាពស្បៀង និង កាត់បន្ថយភាពក្រី ក្រ ។ ការអនុវត្តវារីវប្បកម្មភាគច្រើននៅជុំវិញពិភពលោកបានប្រព្រឹត្តទៅជាមួយនឹងផលប្រយោជន៍

សំខាន់នៃម្ហូបអាហារ និង សង្គម ហើយជាទូទៅជាមួយនឹងតំលៃបរិស្ថានតិចតួច ឬ គ្មានសោះ ។ ប៉ុន្តែវាមានសារៈសំខាន់ណាស់សំរាប់គោលដៅនៃកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នសំរាប់ជោគជ័យវិស័យវារីវប្បកម្មនៅថ្ងៃអនាគតទាំងបណ្តាប្រទេសកំពុងអភិវឌ្ឍ និង ប្រទេសអភិវឌ្ឍ បណ្តាសក្តានុពលសង្គម និង បរិស្ថានគឺជាកត្តាដែលត្រូវបានគិតគូរយ៉ាងត្រឹមត្រូវសំរាប់ធានាថាការអភិវឌ្ឍវារីវប្បកម្មប្រកបដោយស្ថេរភាព ។

ឯកសារនេះផ្តល់ការបកស្រាយពន្យល់ឆ្លើយតបទៅនឹងគោលការណ៍នៃមាត្រា ៩ របស់ក្រមប្រតិបត្តិប្រកបដោយការទទួលខុសត្រូវក្នុងវិស័យជលផល ។ ការបកស្រាយទាំងនេះគឺជាមធ្យោបាយសំរាប់ប្រើប្រាស់ជាការណែនាំទូទៅ ហើយគួរតែទទួលបានយកមកវិញនូវសំណូមពរ ឬ ការអង្កេតបំរុងទុកសំរាប់ជួយជាប្រយោជន៍ក្នុងការកំណត់លក្ខណៈវិនិច្ឆ័យ និង ការជ្រើសរើសសំរាប់សកម្មភាពរបស់គេក្នុងភាពជាដៃគូរដើម្បីសហការណ៍គាំទ្រការអភិវឌ្ឍវារីវប្បកម្មដែលប្រកបដោយនិរន្តរភាព ។

ភាពផ្សេងគ្នានៃវារីវប្បកម្ម ហើយ ពេលខ្លះការយល់ដឹងពី ស្ថេរភាព តុល្យភាព និង ព័ត៌មានជាច្រើនទៀតត្រូវការជាចាំបាច់ដើម្បី ប្រឈមមុខនឹងញ្ហាការអភិវឌ្ឍ និង បរិស្ថាននៅទីកន្លែងជាក់ស្តែងណាមួយ ។ ការប្តេជ្ញាចិត្តដើម្បីធ្វើកិច្ចសហការការសន្ទនាដែលមានប្រយោជន៍រវាងបណ្តាដៃគូរដែលមានការទទួលខុសត្រូវ និង ការចូលរួមរបស់វារីវប្បករ និង សហគមន៍របស់គេគឺជាការចាំបាច់នៅពេលដែលមានការបែងចែកការទទួលខុសត្រូវសំរាប់និរន្តរភាពនៃការអភិវឌ្ឍវារីវប្បកម្ម ។

បង្កលក្ខខណ្ឌងាយស្រួលឱ្យសំរេចទៅបានសំរាប់ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាពគឺជាការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ រដ្ឋាភិបាល និង ស្ថាប័ន សង្គម និង បណ្តាអ្នកវិទ្យាសាស្ត្រ សារព័ត៌មាន ស្ថាប័នហិរញ្ញវត្ថុ បណ្តាក្រុមដែលទទួលផលប្រយោជន៍ពិសេស រាប់បញ្ចូលទាំងបណ្តាវិស័យឯកជន និង សង្គមពាក់ព័ន្ធរបស់គេដូចជា: វារីវប្បករនៃវារីវប្បកម្ម ផលិតករ និង អ្នកផ្គត់ផ្គង់ អ្នកកែច្នៃ និង ពាណិជ្ជករនៃផលិតផលវារីវប្បកម្ម ។ ការប្តេជ្ញាចិត្តស្វែងយល់ត្រឹមត្រូវ និង ឥរិយាបថទទួលខុសត្រូវក្នុងការប្រឹក្សាយោបល់ និង ការចចាររវាងបណ្តាប្រទេស ឬ តំបន់នឹងជួយការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាពផងដែរ ។

មាតិកា ទំព័រ


សារតារ ១

១. សេចក្តីផ្តើម ៥

២.ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវរាប់បញ្ចូលទាំងវារីវប្បកម្ម
ផ្អែកលើផលផលនៅក្នុងតំបន់ដែលស្ថិតក្រោមយុត្តាធិការជាតិ ១២

៣.ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវរាប់បញ្ចូលទាំងវារីវប្បកម្មផ្អែក
លើផលផលក្នុងក្របខណ្ឌកិច្ចចូលឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីនៃវារីសត្វ និង រុក្ខជាតិ ២៥

៤.ការប្រើប្រាស់ប្រភពវារីសេនេទិចសំរាប់គោលបំណងនៃវារីវប្បកម្មរាប់បញ្ចូលទាំង
វារីវប្បកម្មផ្អែកលើផលផល ៣៣

៥. វារីវប្បកម្មដែលប្រកបដោយភាពទទួលខុសត្រូវក្នុងផលិតកម្ម ៤១

៦. ឯកសារបន្ថែក ៥៤

សាវតារ

១. តាំងពីសម័យបុរាណ ការធ្វើអាជីវកម្មនេសាទត្រូវបានចាត់ទុកថាជាប្រភពមួយផ្តល់ម្ហូបអាហារមួយយ៉ាងសំខាន់សំរាប់មនុស្សជាតិ ប្រភពផ្តល់ការងារ និង មានសារៈប្រយោជន៍សេដ្ឋកិច្ចដល់អ្នកដែលចូលរួមក្នុងសកម្មភាពនេះ។ ប៉ុន្តែជាមួយនឹងការកើនឡើងនៃចំណេះដឹង និង ជាមវឌ្ឍនៃការអភិវឌ្ឍវិស័យជលផលត្រូវបានគេដឹងថាប្រភពវារីសត្វ និង រុក្ខជាតិដែលកំពុងរស់នៅ ទោះបីអាចធ្វើឱ្យមានដូចដើមវិញក៏ដោយ ចាំបាច់ត្រូវតែមានការគ្រប់គ្រងឱ្យបានសមស្រប ប្រសិនបើការចូលរួមវិភាគទានក្នុងសេដ្ឋកិច្ច អាហារូបត្ថម្ភ និង សុខុមាលភាពសង្គមនៃការរីកចំរើនប្រជាពលរដ្ឋលើពិភពលោកត្រូវបានគាំទ្រ ។

២. ការយល់ព្រមទទួលស្គាល់សន្ធិសីទនៃសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ក្នុងឆ្នាំ ១៩៨២ បានផ្តល់នូវរចនាសម្ព័ន្ធថ្មី ដើម្បីគ្រប់គ្រងប្រភពធនធានសមុទ្រឱ្យបានកាន់តែប្រសើរជាងមុន។ របបគ្រប់គ្រងមហាសាគរថ្មីត្រឹមត្រូវតាមច្បាប់បានផ្តល់សិទ្ធិ និង ការទទួលខុសត្រូវឆ្នេរសមុទ្ររបស់ប្រទេសដើម្បីគ្រប់គ្រង និង ប្រើប្រាស់ធនធានជលផលនៅក្នុងក្របខ័ណ្ឌនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខដែលរួមបញ្ចូលប្រហែល ៩០% នៃវិស័យជលផលទឹកប្រៃពិភពលោក។

៣. ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ជលផលពិភពលោកបានប្រែក្លាយជាវិស័យមួយដែលកំពុងអភិវឌ្ឍប្រកបដោយជាមវឌ្ឍនៃឧស្សាហកម្មម្ហូបអាហារ ហើយប្រទេសជាច្រើនបានខិតខំយ៉ាងខ្លាំងដើម្បីប្រមូលយកផលប្រយោជន៍ពីឱកាសថ្មីរបស់គេដោយវិនិយោគទុនទៅលើនាវានេសាទទំនើបៗ និង រោងចក្រកែច្នៃ ដើម្បីឆ្លើយតបទៅនឹងតំរូវការកើនឡើងរបស់ត្រី និង ផលិតផលត្រីពីសំណាក់អន្តរជាតិ។ ជាការពិតណាស់ ប្រភពធនធានជាច្រើនមិនអាចទ្រទ្រង់បានទេ ពេលខ្លះមិនទាំងអាចត្រួតពិនិត្យបាននូវកំនើននៃការធ្វើអាជីវកម្មបានផង ។

៤. សញ្ញាយ៉ាងច្បាស់ជាច្រើននៃការធ្វើអាជីវកម្មលើសហួសកំរិតទៅលើសន្និធិត្រីសំខាន់ៗ ការកែប្រែប្រព័ន្ធអេកូឡូស៊ីការបាត់បង់ភាពសំខាន់នៃសេដ្ឋកិច្ចនិងបណ្តឹវិវាទអន្តរជាតិលើកការគ្រប់គ្រង និង ការធ្វើពាណិជ្ជកម្មត្រីបានគំរាមកំហែងដល់និរន្តរភាព និង ការចូលរួមវិភាគទាននៃវិស័យជលផលក្នុងការផ្គត់ផ្គង់ម្ហូបអាហារសំរាប់រយៈពេលយូរអង្វែង ។